Disability Rights California

*ប្រព័ន្ធការការពារ និងការតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*

# នាយកដ្ឋានសេវាកម្មស្តានីតិសម្បទា

*ខែវិច្ឆិកា ឆ្នាំ 2015 អត្ថបទបោះពុម្ពផ្សាយលេខ 5401.06 - Cambodian*

## 1. តើនរណាមានសិទ្ធិទទួលជំនួយពីនាយកដ្ឋានសេវាកម្មស្តានីតិសម្បទា ហើយតើនាយកដ្ឋាននេះធ្វើការសម្រេចដោយរបៀបណា?

ការសម្រេចរបស់នាយកដ្ឋានស្តានីតិសម្បទា (DOR, Department of Rehabilitation) ស្តីអំពីភាពមានសិទ្ធិទទួលបានជំនួយលើសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈ គឺត្រូវផ្អែកលើតែភាពតម្រូវនានាដូចខាងក្រោម ៖

(1) ការសម្រេចដោយបុគ្គលដែលមានគុណសម្បត្តិគ្រប់គ្រាន់ ដែលបុគ្គលនោះមិនចាំបាច់ជាមន្ត្រីរបស់នាយកដ្ឋានឡើយ ដោយបុគ្គលនោះបញ្ជាក់ជូនថា អ្នកដាក់ពាក្យសុំជំនួយជាមនុស្សមានពិការភាពរាងកាយ ឬខួរក្បាល ។ ពាក្យថា "បុគ្គលដែលមានពិការភាព" ("individual with a disability") មានន័យថា អ្នកដាក់ពាក្យសុំជាមនុស្សដែលមានពិការភាពរាងកាយ ឬខួរក្បាល ដែលបង្ករឲ្យមានឧបសគ្គយ៉ាងខ្លាំងចំពោះការងារ ហើយអ្នកដាក់ពាក្យសុំអាចទទួលបានប្រយោជន៍ពីសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈ ។ ក្រមសហរដ្ឋអាមេរិក 29 (U.S.C., United States Code) វគ្គទី 705(20)(A)(i)-(ii); ក្រមសុខុមាលភាព និងវិទ្យាស្ថានកាលីហ្វ័រនីញ៉ា (California Welfare and Institutions Code) វគ្គទី 19151(a)(1)-(2); 9 ក្រមនិយ័តកម្មរដ្ឋកាលីហ្វ័រនីញ៉ា (C.C.R., California Code of Regulations) វគ្គទី 7017(a)(1)-(3)

(2) ការសម្រេចដោយបុគ្គលដែលមានគុណសម្បត្តិគ្រប់គ្រាន់ ដែលបុគ្គលនោះមិនចាំបាច់ជាមន្ត្រីរបស់នាយកដ្ឋានឡើយ ដែលថា ពិការភាពរាងកាយ ឬខួរក្បាលរបស់អ្នកដាក់ពាក្យ វាបង្ករឲ្យមាន ឬនាំឲ្យកើតមានឧសគ្គធ្ងន់ធ្ងរចំពោះការធ្វើការរបស់សាមីខ្លួនជាអ្នកដាក់ពាក្យសុំជំនួយ

(3) ការសម្រេចរបស់អ្នកប្រឹក្សាយោបល់ផ្នែកស្តានីតិសម្បទា (Rehabilitation Counselor) ដែលថាអ្នកដាក់ពាក្យសុំ ត្រូវការសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈ ដើម្បីរៀបចំខ្លួនសម្រាប់ធ្វើការ ក៏ដូចជាជួយឲ្យខ្លួនមានសន្តិសុខការងារ អាចរក្សាការងាររបស់ខ្លួនបាន ឬអាចទទួលបានការងារមកវិញ ដោយផ្អែកលើភាពខ្លាំង ធនធាន អាទិភាព ការព្រួយបារម្ភ លទ្ធភាព សមត្ថភាព ចំណាប់អារម្មណ៍ និងជម្រើសដែលខ្លួនបានដឹង និង

(4) ការសន្មតជាមុនថា អ្នកដាក់ពាក្យអាចទទួលបានប្រយោជន៍ពីការផ្តល់ជូនសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈ ពាក់ព័ន្ធនឹងលទ្ធផលការងារនៅក្នុងបរិយាកាសរួមបញ្ចូលគ្នា ។

9 C.C.R. វគ្គទី 7062(a) ។ បើអ្នកជាអ្នកទទួល ឬជាក្រុមគោលដៅរបស់ប្រាក់ចំណូលសន្តិសុខ បង្គ្រប់ (SSI, Supplemental Security Income) និង/ឬ ការធានារ៉ាប់រងពិការភាពសន្តិសុខសង្គម (SSDI, Social Security Disability Insurance) គឺមានន័យជាមុនថា អ្នកអាចមានសិទ្ធិទទួលបានសេវាកម្មនេះ ។ 29 U.S.C. វគ្គទី 722(a)(3)(A)(i)-(ii); ក្រមនិយត្តកម្មសហព័ន្ធ 34 (C.F.R., Code of Federal Regulations) វគ្គទី 361.42(a)(3)(i)(A)-(B) ។ ទោះជាយ៉ាងណាក៏ដោយ បើពិការភាពរបស់អ្នកមានសភាពធ្ងន់ធ្ងរ រហូតដល់សេវាកម្មរបស់នាយកដ្ឋានស្តានីតិសម្បទាមិនអាចជួយរកការងារឲ្យអ្នកធ្វើបាន យើងខ្ញុំសូមបដិសេធមិនផ្តល់សេវាកម្មដល់អ្នកឡើយ ។

ដើម្បីបដិសេធមិនផ្តល់សេវាកម្ម នាយកដ្ឋានស្តានីតិសម្បទា ត្រូវតែ “បង្ហាញភស្តុតាងឲ្យច្បាស់ និងគួរឲ្យជឿជាក់បានដែលថាបុគ្គលក្នុងស្ថានភាពនេះមិនមានសមត្ថភាពអាចទទួលបានប្រយោជន៍ការងារពីសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈដោយសារស្ថានភាពពិការភាពធ្ងន់ធ្ងររបស់គេ” ។ 29 U.S.C. វគ្គទី 722(a)(2)(A) 34 C.F.R. វគ្គទី 361.42(a)(2) ក្រមសុខមាលភាព និងវិទ្យាស្ថាន (W.I.C., Welfare and Institutions Code) វគ្គទី 19103(b) និង 9 C.C.R. វគ្គទី 7062(c) ។

សម្រាប់ព័ត៌មានបន្ថែមអំពីភាពមានសិទ្ធិទទួលជំនួយ សូមអានឯកសារការពិតរបស់នាយកដ្ឋានសេវាកម្មស្តានីតិសម្បទា (Eligibility for Department of Rehabilitation Services Fact Sheet) ឯកសារបោះពុម្ពផ្សាយលេខ F06601 តាមអាសយដ្ឋាន ៖ http://www.disabilityrightsca.org/pubs/06601.pdf

## 2. តើនាយកដ្ឋានស្ដានីតិសម្បទាអាចសម្រេចដោយរបៀបណាថាតើខ្ញុំមានសិទ្ធទទួលសេវាកម្មដែរឬទេ ប្រសិនបើខ្ញុំមិនបានទទួលអ្វីពីរដ្ឋបាលបេឡាសន្តិសុខសង្គមទេនោះ?

នៅក្នុងដំណើរការកំណត់ភាពមានសិទ្ធិទទួលសេវាកម្ម អ្នកប្រឹក្សាយោបល់ផ្នែកស្ដានីតិសម្បទា អាចយកកំណត់ត្រាព័ត៌មានរបស់ភ្នាក់ងារដទៃមកពិចារណា ត្រង់នេះគឺបូករួមទាំងការវាយតម្លៃស្ថានភាពពិការភាព ដើម្បីកំណត់ថាតើអ្នកមានសិទ្ធិទទួលសេវាកម្មពីភ្នាក់ងារទាំងនោះដែរឬទេ ។ អ្នកប្រឹក្សាយោបល់ក៏អាចពិនិត្យមើលសេចក្ដីថ្លែងដែលសរសេរឡើងដោយអ្នកមានវិជ្ជាជីវៈដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលជាអ្នកធ្វើរោគវិនិច្ឆ័យ ឬជាអ្នកព្យាបាលរូបអ្នក ។

បើអ្នកមានឯកសារប្រភេទនេះ អ្នកអាចយកវាមកបង្ហាញដល់អ្នកប្រឹក្សាយោបល់ ។

## 3. តើពិការភាពប្រភេទណាដែលចាត់ទុកថាបង្ករឲ្យមានឧបសគ្គធ្ងន់ធ្ងរចំពោះការងារ?

“ឧបសគ្គធ្ងន់ធ្ងរចំពោះការងារ” (Substantial Impediment to Employment) មានន័យថា ជាពិការភាពរាងកាយ ឬពិការភាពខួរក្បាល (ពាក់ព័ន្ធនឹងកត្តាវេជ្ជសាស្ត្រ ចិត្តសាស្ត្រ វិជ្ជាជីវៈ ការអប់រំ ការទំនាក់ទំនង និងកត្តាផ្សេងៗទៀតដែលពាក់ព័ន្ធ) ដែលធ្វើឲ្យបុគ្គលមិនអាចត្រៀមខ្លួនដើម្បីធ្វើការ ក៏ដូចជាដើម្បីចូលខ្លួនក្នុងវិស័យការងារ បំពេញការងារ ឬរក្សាបាននូវការងារដោយអនុលោមទៅតាមលទ្ធភាព និងសមត្ថភាពរបស់បុគ្គលនោះ ។ 9 C.C.R. វគ្គទី 7027 ។

ពិការភាពបណ្ដោះអាសន្ន នឹងមិនត្រូវបានគិតថាជាឧបសគ្គធ្ងន់ធ្ងរចំពោះការងារឡើយ ។ *សូមអាន Paegle v. DOI*, 813 F ។ Supp. 61 (D.D.C. 1993) ។

## 4. តើការវាយតម្លៃប្រភេទណាដែលនាយកដ្ឋានស្ដានីតិសម្បទាអាចធ្វើឡើងដើម្បីកំណត់ពីភាពមានសិទ្ធិទទួលសេវាកម្មរបស់ខ្ញុំ?

ដើម្បីកំណត់ពីភាពមានសិទ្ធិទទួលសេវាកម្ម និងពីតម្រូវការស្ដានីតិសម្បទាវិជ្ជាជីវៈរបស់បុគ្គលណាមួយ អ្នកប្រឹក្សាយោបល់ត្រូវពិនិត្យកំណត់ត្រាព័ត៌មានដែលមានស្រាប់ ស្នើសុំឲ្យអ្នកចូលរួមក្នុងការ

វាយតម្លៃបែបទូលំទូលាយ បូករួមទាំងការវាយតម្លៃលើការសាកល្បងការងារ និងធ្វើការបញ្ជូនអ្នកទៅកាន់កន្លែងផ្តល់សេវាកម្ម ។ 29 U.S.C. វគ្គទី 705(2)(A)-(D) ។ អាស្រ័យលើភាពចាំបាច់ដែលត្រូវការ ដើម្បីសម្រេចអំពីលទ្ធផលការងារ និងលក្ខណ:ពិការភាព ព្រមទាំងកម្រិតត្រូវការសេវាកម្ម ស្តានីតិសម្បទាវិជ្ជាជីវ:ដែលនាយកដ្ឋានត្រូវផ្តល់ជូន អ្នកប្រឹក្សាយោបល់ អាចវាយតម្លៃដូចខាងក្រោម ៖

> ចរិកលក្ខណ: ចំណាប់អារម្មណ៍ បំណិនអន្តរបុគ្គល ភាពឆ្លាតវៃ និងសមត្ថភាពមុខងារផ្សេងៗទៀតដែលពាក់ព័ន្ធ របស់រាងកាយភាពសម្រេចបានលើការសិក្សា បទពិសោធន៍ការងារ សមត្ថភាពធម្មជាតិចំពោះការងារ ការសម្របខ្លួន និងការសម្របខ្លួនក្នុងសង្គម ព្រមទាំងឱកាសការងារ ... និងកត្តាវេជ្ជសាស្ត្រ កត្តាវិកលចរិក កត្តាចិត្តសាស្ត្រ និងកត្តាផ្សេងៗទៀតដែលទាក់ទងនឹងវិជ្ជាជីវ: ការអប់រំ វប្បធម៌ សង្គម ការកំសាន្ត និងកត្តាបរិស្ថាន ដែលប៉ះពាល់ចំពោះតម្រូវការការងារ និងការស្តានីតិសម្បទា ...
>
> 29 U.S.C. វគ្គទី 705(2)(B)(iii) ។

វាមិនមែនជាបញ្ជីដែលបញ្ចប់ត្រឹមនេះឡើយ ។ ច្បាប់បានអនុញ្ញាតឲ្យនាយកដ្ឋានស្តានីតិសម្បទានូវសេរីភាពទូលំទូលាយក្នុងការធ្វើការវាយតម្លៃបែបនេះ ។ សេរីភាពនេះ ត្រូវបង្វែរឲ្យទៅជាការវាយតម្លៃដែលមានភាពសមរម្យចំពោះតម្រូវការស្តានីតិសម្បទាវិជ្ជាជីវ:របស់អ្នក ។ ទោះជាយ៉ាងណាក៏ដោយ ការវាយតម្លៃនេះត្រូវតែកំណត់ត្រឹមព័ត៌មានដែលចាំបាច់សម្រាប់កំណត់រកតម្រូវការស្តានីតិសម្បទាររបស់អ្នក និងដើម្បីអភិវឌ្ឍន៍ផែនការតម្រូវតាមលក្ខណ: បុគ្គលសម្រាប់ការងារ (IPE, Individualized Plan for Employment) របស់អ្នក ។ នាយកដ្ឋានស្តានីតិសម្បទា ត្រូវប្រើព័ត៌មានដែលមានស្រាប់ និងព័ត៌មានដែលអ្នកផ្តល់ជូនឲ្យបានតាមតម្រូវការជាអតិបរមា តាមដែលអាចធ្វើទៅបាន ។. 9 C.C.R វគ្គទី 7001.5 (c) ។

## 5. តើត្រូវធ្វើដូចម្ដេច បើខ្ញុំត្រូវការភាពសម្រួល ឬសេវាកម្មអ្វីមួយ ទើបអាចចូលរួមក្នុងការវាយតម្លៃបាន?

នាយកដ្ឋានស្ដានីតិសម្បទា ត្រូវធ្វើការវាយតម្លៃ ទៅតាមស្ថានភាពបញ្ចូលគ្នាឲ្យបានច្រើនជាទីបំផុត ដែលមានភាពស្របគ្នាជាមួយនឹងតម្រូវការ និងជម្រើសដែលអ្នកបានដឹង ។ 9 C.C.R. វគ្គទី 7062 ។ ការវាយតម្លៃនេះ ត្រូវរួមបញ្ចូលការជ្រោមជ្រែងសមរម្យដែលនាយកដ្ឋានជាអ្នកផ្ដល់ជូន បូករួមទាំងឧបករណ៍បច្ចេកវិជ្ជាសម្រាប់ជំនួយ និងសេវាកម្ម ព្រមទាំងសេវាកម្មជំនួយផ្ទាល់ខ្លួន ដើម្បីសម្រួលដល់តម្រូវការស្ដានីតិសម្បទារបស់អ្នក ។ 9 C.C.R. វគ្គទី 7014(c) និង 7029.1(b)(4) ។

លើសពីនេះ អ្នកមានសិទ្ធិទទួលបានការសម្រួលប្រកបដោយភាពសមរម្យ នៅក្នុងដំណើរការស្ដានីតិសម្បទាវិជ្ជាជីវៈពីដើមដល់ចប់របស់អ្នក ។ ក្រោមច្បាប់ Title II នៃក្រមពិការភាពអាមេរិកាំង (ADA, Americans with Disabilities Act) និងវគ្គទី 504 នៃក្រមស្ដានីតិសម្បទា ឆ្នាំ 1973 (Rehabilitation Act of 1973) អង្គភាពសាធារណ: ឬអង្គភាពដែលទទួលជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាលសហព័ន្ធ ដូចជានាយកកដ្ឋានស្ដានីតិសម្បទា ត្រូវតែធ្វើការសម្រួល ឲ្យបានសមរម្យនៅក្នុងគោលនយោបាយ ការអនុវត្ត និងទម្រង់ការដែលចាំបាច់ ដើម្បីអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំសេវាកម្ម និងអតិថិជនដែលមានពិការភាពជាប់ខ្លួន អាចទទួលបានសេវាកម្មរបស់នាយកដ្ឋានស្ដានីតិសម្បទា ។

ប្រសិនបើអ្នកកំពុងតែស្នើសុំសេវាកម្មដើម្បីធ្វើការវាយតម្លៃ និង/ឬស្នើសុំសេវាកម្មសម្រួលពីនាយកដ្ឋានស្ដានីតិសម្បទា យើងខ្ញុំសូមណែនាំឲ្យអ្នកធ្វើសំណើជាលាយល័ក្ខណ៍អក្សរ ហើយរក្សាទុកមួយច្បាប់ជាសំណៅរបស់ខ្លួន ។

## 6. តើខ្ញុំអាចដាក់ពាក្យសុំសេវាកម្មរបស់នាយកដ្ឋាន ស្ដានីតិសម្បទាបានដោយរបៀបណា?

ដាក់ពាក្យសុំតាមរយៈ ៖

- ធ្វើដំណើរមកកាន់ការិយាល័យស្ដានីតិសម្បទាក្នុងមូលដ្ឋានរបស់អ្នក
- ដាក់ពាក្យសុំតាមអនឡាញ តាមអាសយដ្ឋាន https://www.dor.ca.gov/Apply-4-Services.html

- ហៅទូរស័ព្ទមកកាន់ការិយាល័យស្ដានីតិសម្បទា ហើយស្នើសុំពាក្យសុំសេវាកម្ម ឬ

- សរសេរលិខិតមកកាន់ការិយាល័យស្ដានីតិសម្បទា ហើយស្នើសុំសេវាកម្ម ។

អ្នកអាចស្វែងរកលេខទូរស័ព្ទ និងអាសយដ្ឋានការិយាល័យស្ដានីតិសម្បទាប្រចាំមូលដ្ឋានរបស់អ្នក តាមអាសយដ្ឋាន https://www.dor.ca.gov/dor-locations/index.asp

យើងខ្ញុំសូមណែនាំអ្នកឲ្យរក្សាទុកសំណៅពាក្យសុំដែលមានចុះហត្ថលេខារបស់អ្នក ឬក៏រក្សាទុកឯកសារស្នើសុំរបស់អ្នក ដោយមានសរសេរកាលបរិច្ឆេទចូលផងដែរ ។

## 7. តើនាយកដ្ឋានស្ដានីតិសម្បទាត្រូវចំណាយពេលយូរប៉ុណ្ណាដើម្បីដំណើរការពាក្យសុំរបស់ខ្ញុំ?

ជាទូទៅ នាយកដ្ឋានស្ដានីតិសម្បទា ត្រូវតែកំណត់ពីភាពមានសិទ្ធិទទួលសេវាកម្មរបស់អ្នកក្នុងរវាង 60 ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទក្នុងពាក្យសុំរបស់អ្នក ។ 29 U.S.C. វគ្គទី 722(a)(6)  34 C.F.R. វគ្គទី 361.41(b)(1) 9 C.C.R. វគ្គទី 7060(a) ។ នាយកដ្ឋានស្ដានីតិសម្បទា អាចចំណាយពេលច្រើនជាង 60 ថ្ងៃ ក្នុងករណី ៖

- មានហេតុការណ៍ពិសេស ឬហេតុការណ៍ដែលមិនបានគិតដល់បានកើតឡើង ដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់នាយកដ្ឋានស្ដានីតិសម្បទា

- បើអ្នកដាក់ស្នើសំណើជាលាយល័ក្ខណ៍អក្សរសូមពន្យារពេល

- ព័ត៍មានត្រូវតែទទួលបានតាមរយៈបទពិសោធន៍សាកល្បងការងារ ទើបអាចកំណត់បានអំពីភាពមានសិទ្ធិទទួលសេវាកម្មរបស់អ្នក ឬ

- ការវាយតម្លៃដែលត្រូវបានពន្យាពេល គឺជាភាពចាំបាច់ ហើយមិនអាចទទួលបានក្នុងរវាង 60 ថ្ងៃទេ ។

34 C.F.R. វគ្គទី 361.41(b)(1)(i) និង (ii) 9 C.C.R. វគ្គទី 7060(a)(1)-(2) ។

បើអ្នកមិនយល់ស្របជាមួយនឹងសេចក្ដីសម្រេចរបស់នាយកដ្ឋានស្ដានីតិសម្បទាក្នុងការពន្យារបន្ទាត់ពេលវេលាកំណត់ភាពមានសិទ្ធិទទួលសេវាកម្មរបស់អ្នកទេ នាយកដ្ឋានស្ដានីតិសម្បទា ត្រូវធ្វើសេចក្ដីសម្រេចដោយផ្អែកលើព័ត៍មានបច្ចុប្បន្នដែលខ្លួនមាន ។ C.C.R. 9 វគ្គទី 7060(b) ។

## 8. តើខ្ញុំត្រូវរស់នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ាយូរប៉ុណ្ណា ទើបអាចមានសិទ្ធិទទួលសេវាកម្មនេះ?

ច្បាប់របស់រដ្ឋាភិបាលសហព័ន្ធបានចែងថា នាយកដ្ឋានស្តានីតិសម្បទា មិនអាចប្រើពេលវេលាចំពោះការរស់នៅក្នុងរដ្ឋ យកមកធ្វើជាលក្ខ័ណ្ឌដើម្បីកំណត់ភាពមានសិទ្ធិទទួលសេវាកម្មបានឡើយ ។ 34 C.F.R. វគ្គទី 361.42(c) ។ បទបញ្ញត្តិរបស់រដ្ឋកាលីហ្វ័រនីញ៉ា បានបញ្ជាក់ថា មិនតម្រូវឲ្យមានលក្ខ័ណ្ឌចំពោះការស្នាក់នៅ ដើម្បីជាគំនាបមិនឲ្យបុគ្គលណាមួយដែលមានវត្តមាននៅក្នុងរដ្ឋ ពីការមិនអាចទទួលសេវាកម្មបានឡើយ ។ 9 C.C.R. វគ្គទី 7060(c)(1) ។

## 9. តើគេអាចបដិសេធមិនផ្តល់សេវាកម្មឲ្យខ្ញុំ ដោយសារអាយុ ពូជសាសន៍ ភេទ សាសនា ឬពិការភាពដែរឬទេ?

ទេ ។ នាយកដ្ឋានស្តានីតិសម្បទា ត្រូវបានទទួលការហាមប្រាមមិនឲ្យប្រើអាយុ ពូជសាសន៍ ជំនឿសាសនា ពណ៌សម្បុរ ដូនតា សញ្ជាតិដើម ទំនោរភេទ ស្ថានភាពគ្រួសារ ស្ថានភាពសុខភាព ឬពិការភាពកាយ ឬពិការភាពខួរក្បាល ជាលក្ខ័ណ្ឌតម្រូវក្នុងការទទួលសេវាកម្មឡើយ ។ 34 C.F.R. វគ្គទី 361.42(c)(2) 9 C.C.R. វគ្គទី 7060(c)(2) ។

## 10. តើខ្ញុំអាចទទួលបានសេវាកម្មបែបណា?

ទៅតាមភាពសមរម្យនៃតម្រូវការស្តានីតិសម្បទារបស់បុគ្គលម្នាក់ៗ និងមានភាពស្របគ្នាជាមួយនឹងជម្រើសរបស់បុគ្គលម្នាក់ៗ អ្នកអាចទទួលបានសេវាកម្មដូចខាងក្រោម តែក៏មិនកំណត់តែចំពោះ ៖

a) ការវាយតម្លៃដើម្បីកំណត់ភាពមានសិទ្ធិទទួលសេវាកម្ម និងអាទិភាពដើម្បីទទួលសេវាកម្ម

b) ការវាយតម្លៃដើម្បីកំណត់អំពីតម្រូវការស្តានីតិសម្បទាវិជ្ជាជីវៈ

c) ការប្រឹក្សាយោបល់អំពីការស្តានីតិសម្បទាវិជ្ជាជីវៈ ព្រមទាំងគោលការណ៍ណែនាំ បូករួមទាំងព័ត៌មាន និងសេវាកម្មជ្រោមជ្រែង

d) ការបញ្ជូនបន្ត និងសេវាកម្មផ្សេងទៀតដែលចំបាច់ ក្នុងការជួយដល់អ្នកដាក់ពាក្យសុំ និងបុគ្គលដែលមានសិទ្ធិទទួលបានសេវាកម្ម ដើម្បីធានាបាននូវសេវាកម្មដែលអ្នកត្រូវការពីភ្នាក់ងារផ្សេងទៀត ;

e) សេវាកម្មការធ្វើឲ្យរាងកាយ និងខួរក្បាលត្រឡប់ទៅរកសភាពដើមវិញ ទៅតាមកម្រិតដែលការជ្រោមជ្រែងហិរញ្ញវត្ថុពីប្រភពផ្សេងទៀតនៅមិនទាន់អាចផ្តល់ជូនបាន ក្រៅពីប្រភពពីនាយកដ្ឋាន

f) សេវាកម្មបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាកម្មបណ្តុះបណ្តាលផ្សេងៗទៀត

g) មានការផ្តល់ជូនមធ្យោបាយធ្វើដំណើរ ដើម្បីជួយឲ្យអ្នកមានលទ្ធភាពអាចចូលរួមទទួលសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈណាមួយ

h) សេវាកម្មបកប្រែភាសា

i) សេវាកម្មអាន សេវាកម្មបង្រៀនវិជ្ជាជីវៈ និងការណែនាំការងារ ព្រមទាំងសេវាកម្មចល័ត សម្រាប់ពលរដ្ឋដែលពិការភ្នែក

j) សេវាកម្មពាក់ព័ន្ធនឹងការងារ

k) សេវាកម្មជ្រោមជ្រែងការងារ

l) សេវាកម្មក្រោយចប់ការងារ

m) អាជ្ញាប័ណ្ណមុខរបរ ឧបករណ៍ និងសម្ភារៈ

n) បច្ចេកវិជ្ជាស្តានីតិសម្បទា

o) សេវាកម្មអន្តរកាល

p) ជំនួយបច្ចេកទេស និងសេវាកម្មប្រឹក្សាយោបល់ផ្សេងទៀត ចំពោះបុគ្គលណាដែលមានសិទ្ធិ ដែលត្រូវការ បង្កើតមុខរបរដោយខ្លួនឯង ឬការធ្វើការពីផ្ទះ (មិនបាច់ទៅការិយាល័យ) ឬការបង្កើតប្រតិបត្តិការមុខរបរខ្នាតតូច សម្រាប់ជាលទ្ធផលការងារ

q) របស់របរ និងសេវាកម្មផ្សេងៗទៀតដែលត្រូវបានកំណត់ឃើញថាមានភាពចាំបាច់ចំពោះបុគ្គលដែលមានពិការភាពជាប់ខ្លួនដើម្បីធ្វើឲ្យពួកគេអាចសម្រេចបានលទ្ធផលការងារ ។

9 C.C.R. វគ្គទី 7149 ។

## 11. តើខ្ញុំត្រូវបង់ថ្លៃចំពោះសេវាកម្មទាំងនេះដែរឬទេ?

បើអ្នកមានប្រាក់ចំណូល អ្នកអាចត្រូវបង់ថ្លៃសេវាកម្មខ្លះៗ ។ 34 C.F.R. វគ្គទី 361.54(b)(1) ។ ដើម្បីកំណត់ថាតើអ្នកត្រូវចូលរួមចេញការចំណាយថ្លៃសេវាកម្មដែរឬទេ នាយកដ្ឋានស្តានីតិសម្បទា ត្រូវការព័ត៌មានពីអ្នកស្តីអំពីប្រាក់ចំណូល

ប្រចាំខែរបស់អ្នក ទ្រព្យធនដែលងាយបង្វែរជាសាច់ប្រាក់ និងការចំណាយថ្លៃថែទាំសុខភាពរបស់អ្នក ។ 9 C.C.R. វគ្គទី 7192(b) ។

បើអ្នកបដិសេធមិនចូលរួមចេញថ្លៃចំណាយលើសេវាកម្មទេ នាយកដ្ឋានស្ដានីតិសម្បទាអាចបដិសេធមិនផ្ដល់សេវាកម្មទាំងនោះដល់អ្នក ។ C.C.R. 9 វគ្គទី 7190(b) ។

## 12. បើខ្ញុំបានទទួលប្រាក់សន្តិសុខសង្គម តើខ្ញុំត្រូវចូលរួមចេញការចំណាយលើថ្លៃសេវាកម្មរបស់ខ្ញុំដែរឬទេ?

បើអ្នកទទួលបាន SSI, SSDI, ប្រាក់បង់ បង្គ្រប់របស់រដ្ឋ (SSP, State Supplemental Payment) ឬប្រាក់ជំនួយសាធារណៈ (Public Assistance) គឺអ្នកត្រូវរួចខ្លួនមិនចាំបាច់បង់ថ្លៃសេវាកម្មឡើយ ។ 9 C.C.R. វគ្គទី 7191(a ។

## 13. តើត្រូវធ្វើដូចម្ដេច បើខ្ញុំមិនមានប្រាក់គ្រប់គ្រាន់ជួយចេញថ្លៃសេវាកម្ម?

យោងទៅតាមបទបញ្ញត្តិរបស់សហព័ន្ធ ថ្លៃដែលអ្នកត្រូវជួយចេញការចំណាយសេវាកម្មចំពោះសេវាកម្មនាយកដ្ឋានស្ដានីតិសម្បទា មិនអាចមានចំនួនច្រើនរហូតដល់អ្នកមិនមានលទ្ធភាពទទួលបានសេវាកម្មដែលចាំបាច់ឡើយ ។ 34 C.F.R. វគ្គទី 361.54(b)(2)(iv)(C) ។

## 14. តើអ្វីជាផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ?

ផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ (IPE) គឺជាកិច្ចព្រមព្រៀងមួយដែលរួមគ្នាសរសេរដោយអតិថិជន និងអ្នកប្រឹក្សាយោបល់របស់សាមខ្លួន មកពីនាយកដ្ឋានស្ដានីតិសម្បទា ។ ផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ គឺជាផែនការសកម្មភាពដែលបានរៀបចំឡើង ដើម្បីសម្រេចបានគោលបំណងវិជ្ជាជីវៈ ឬដើម្បីអនុវត្តការវាយតម្លៃបន្ថែម ដើម្បីកំណត់រកឲ្យឃើញនូវសក្ដានុពលការងាររបស់អ្នក ។ សូមអានចំណុចទូទៅនៃ 9 C.C.R. វគ្គទី 7131 ។

សម្រាប់ព័ត៍មានបន្ថែមអំពីផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ សូមអានឯកសារការពិតស្ដីអំពីផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ (Individualized Plan for Employment Fact Sheet) ឯកសារបោះពុម្ពផ្សាយលេខ F06801 តាមអាសយដ្ឋាន ៖ http://www.disabilityrightsca.org/pubs/06801.pdf

## 15. តើគួរសរសេរអ្វីខ្លះក្នុងផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ?

នៅក្នុងផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ គួររៀបរាប់អំពីលទ្ធផលការងាររបស់អ្នក សេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈជាក់លាក់ដែលនាយកដ្ឋានស្តានីតិសម្បទាត្រូវផ្តល់ជូន និងរបៀបដែលនាយកដ្ឋានស្តានីតិសម្បទានាំសេវាកម្មទាំងនោះមកឲ្យអ្នក ។ ច្បាប់តម្រូវឲ្យមានសរសេរលក្ខ័ណ្ឌជាក់លាក់នៅក្នុងផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់អ្នក ។ ឧទាហរណ៍ នៅក្នុងផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ ត្រូវមានសរសេរចូលនូវ ៖

- មូលដ្ឋានសម្រាប់ការសម្រេចរបស់នាយកដ្ឋានស្តានីតិសម្បទាចំពោះសិទ្ធិទទួលបានសេវាកម្មរបស់អ្នក
- គោលបំណងរបស់អ្នកក្នុងរយៈពេលខ្លី
- គោលបំណងក្នុងរយៈពេលវែងរបស់អ្នក
- ក្របខ័ណ្ឌពេលវេលាដែលត្រូវសម្រេចគោលបំណងក្នុងរយៈពេលខ្លី
- សេវាកម្មជាក់លាក់ដែលនាយកដ្ឋានស្តានីតិសម្បទាត្រូវផ្តល់ឲ្យអ្នក
- ពេលវេលាដែលសេវាកម្មនីមួយៗ ត្រូវផ្តល់ជូន និងថិរវេលាដែលត្រូវផ្តល់ជូន
- កាលវិភាគអំពីពេលវេលា និងរបៀបត្រួតពិនិត្យការរីកចម្រើនរបស់អ្នក និង
- ទស្សនៈរបស់អ្នកអំពីទិសដៅរបស់អ្នក

សូមអានជាទូទៅក្នុង 34 C.F.R. វគ្គទី 361.46 9 C.C.R. វគ្គទី 7131 ។

ផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ គួរតែមានការពណ៌នាអំពីការទទួលខុសត្រូវរបស់អ្នក ។ ឧទាហរណ៍ ការទទួលខុសត្រូវពាក់ព័ន្ធនឹងការសម្រេចបានលទ្ធផលការងារ កម្រិតដែលអ្នកត្រូវជួយចេញថ្លៃសេវាកម្ម និងការទទួលខុសត្រូវរបស់អ្នកដើម្បីដាក់ពាក្យសុំ និងប្រើប្រាស់អត្ថប្រយោជន៍ដែលស្រដៀងគ្នានេះ ។ 34 C.F.R. វគ្គទី

361.46(a)(6)(ii) ។ ផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ ត្រូវមានរួមបញ្ចូលនូវសេចក្តីថ្លែង ស្តីអំពីការទទួលខុសត្រូវរបស់នាយកដ្ឋានស្តានីតិសម្បទា និងភ្នាក់ងារដទៃទៀតដែលជួយដល់អ្នក ។ 34 C.F.R. វគ្គទី 361.46(a)(6)(i) និង (iii) ។

## 16. តើអ្នកមានសិទ្ធិចូលរួមក្នុងការសរសេរផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារដែរឬទេ?

មាន ។ ផែនការតម្រូវតាមលក្ខណៈបុគ្គលត្រូវតែសរសេររួមគ្នា រវាងអ្នកប្រឹក្សាយោបល់ *និង* អតិថិជន ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន វគ្គទី 19104(b)(2) ។ អ្នកត្រូវចូលរួមយ៉ាងសកម្មក្នុងការសរសេរផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់អ្នក ពីព្រោះអ្នកត្រូវជ្រើសរើសលទ្ធផលការងាររបស់អ្នក ។ 34 C.F.R. វគ្គទី 361.45(b)(2) & 361.46(a)(1) ។
បើអ្នកមិនសប្បាយចិត្តចំពោះផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់អ្នកទេ អ្នកអាចបង្ហាញពីភាពមិនពេញចិត្តរបស់អ្នក ហើយអ្នកអាចស្វែងរកអន្តរាគមន៍ផ្នែករដ្ឋបាល ឬផ្នែកច្បាប់ ។ អានចំណុចទូទៅនៃ 29 U.S.C. វគ្គទី 722(c) 9 C.C.R. វគ្គទី 7350-7361 ។

## 17. តើនាយកដ្ឋានស្តានីតិសម្បទា អាចបដិសេធក្នុងការផ្តល់សេវាកម្មពីប្រភពផ្សេងជូនអ្នកបានដែរឬទេ?

អាច ។ ក្រោមច្បាប់សហព័ន្ធ នាយកដ្ឋានត្រូវធានាថា ខ្លួនបានស្វែងរកសេវាកម្មដែលផ្តល់ជូនដោយកម្មវិធីផ្សេងដែលមានភាពស្រដៀងគ្នា នៅមុនពេលខ្លួនផ្តល់ជូនសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈដល់អ្នក ។ ត្រង់នេះមានន័យថា នាយកដ្ឋានស្តានីតិសម្បទា នឹងមិនចេញថ្លៃសេវាកម្មណាមួយទេ ប្រសិនបើសេវាកម្មដែលដូចគ្នា ឬដែលស្រដៀងគ្នា មានផ្តល់ជូនដោយអ្នកផ្តល់សេវាកម្មដទៃទៀត ។

អ្នកប្រឹក្សាយោបល់របស់នាយកដ្ឋានស្តានីតិសម្បទា ត្រូវជួយអតិថិជន ក្នុងការកំណត់ថាតើផលប្រយោជន៍ណាដែលស្រដៀងគ្នាដែលប្រភពផ្សេងជាអ្នកផ្តល់ជូន តាមរយៈការពិនិត្យឡើងវិញអំពីផលប្រយោជន៍ដែលស្រដៀងគ្នា ។ ក្រមសុខុមាលភាព និងវិទ្យាស្ថាន វគ្គទី 19150(a)(13) ។ ប្រសិនបើមានអត្ថប្រយោជន៍ដែលស្រដៀងគ្នា អ្នកប្រឹក្សាយោបល់ត្រូវ

បដិសេធផលប្រយោជន៍ដែលអតិថិជនស្នើសុំមកកាន់នាយកដ្ឋានស្តានីតិសម្បទា ។ ក្រម 9 C.C.R. វគ្គទី 7196(c)(1) ។

នៅពេលដែលអតិថិជនត្រូវបានបដិសេធពីសិទ្ធិទទួលសេវាកម្ម ផ្សេងដែលស្រដៀងគ្នា នោះអ្នកប្រឹក្សាយោបល់របស់នាយកដ្ឋានស្តានីតិសម្បទា ត្រូវតែបំពេញចំណុចដូចខាងក្រោម ៖

- ផ្ទៀងផ្ទាត់ចំពោះភាពគ្មានសិទ្ធិទទួលសេវាកម្មរបស់អតិថិជន ដោយការទាក់ទងជាមួយនឹងភ្នាក់ងារដែលបដិសេធមិនផ្តល់សេវាកម្ម

- ចងក្រងឯកសារការផ្ទៀងផ្ទាត់ និង

- បញ្ជាសេវាកម្មចេញពីនាយកដ្ឋានស្តានីតិសម្បទា ។

C.C.R. 9 វគ្គទី 7196 (d)(1)(A)-(C) ។

ប្រសិនបើអតិថិជនបានទទួលផលប្រយោជន៍ដែលស្រៀងគ្នារួចហើយ ត្រូវកាត់បន្ថយ ឬបញ្ចប់សេវាកម្ម ដែលភ្នាក់ងារផ្សេងជាអ្នកផ្តល់ជូន ពេលនោះអ្នកប្រឹក្សាយោបល់ត្រូវតែ ៖

- ផ្ទៀងផ្ទាត់ពីភាពគ្មានសិទ្ធិទទួលសេវាកម្មរបស់អតិថិជន

- ចងក្រងឯកសារស្តីពីភាពគ្មានសិទ្ធិទទួលសេវាកម្មរបស់អតិថិជន

- វាយតម្លៃកាលៈទេសៈជាមួយអតិថិជន

- បញ្ជាសេវាកម្មចេញពីនាយកដ្ឋានស្តានីតិសម្បទា ចំពោះសេវាកម្មដែលត្រូវកាត់បន្ថយ ឬបញ្ចប់ និង

- កែប្រែផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ ។

9 C.C.R. វគ្គទី 7196 (d)(2)(A)-(C) ។

## 18. តើមានហេតុផលផ្សេងទៀតដែលនាយកដ្ឋានស្តានីតិសម្បទាអាចបដិសេធមិនផ្តល់សេវាកម្មឲ្យខ្ញុំដែរឬទេ?

អាច ។ នាយកដ្ឋានស្តានីតិសម្បទា កំណត់នូវសេវាកម្មអ្វីដែលអ្នកត្រូវការ ដោយអាស្រ័យលើការវាយតម្លៃអំពីតម្រូវការស្តានីតិសម្បទាវិជ្ជាជីវៈ និងលទ្ធផលការងាររបស់អ្នក ។ 9 C.C.R. វគ្គទី 7128 ។ ប្រសិនបើនាយកដ្ឋាន

ស្ថានីតិសម្បទាបានកំណត់ឃើញថា អ្នកមិនត្រូវការសេវាកម្មដោយអាស្រ័យថា ពិការភាព និង/ឬសេវាកម្មនោះ វាមិនមានភាពចាំបាច់សម្រាប់អ្នក ដើម្បីសម្រេចគោលបំណងការងារទេនោះ នាយកដ្ឋានស្ថានីតិសម្បទា អាចបដិសេធមិនផ្តល់សេវាកម្មនោះឲ្យអ្នក ។

បើអ្នកមិនយល់ស្របជាមួយនឹងការសម្រេចរបស់នាយកដ្ឋានស្ថានីតិសម្បទាទេ អ្នកមានសិទ្ធិប្តឹងឧទ្ធរណ៍បាន ។ (*សូមអាន* សំណួរ 32-38) ។

## 19. ខ្ញុំត្រូវការបង្កើតមុខរបរដោយខ្លួនឯង ។ តើនាយកដ្ឋានស្ថានីតិសម្បទា នៅតែអាចផ្តល់សេវាកម្មឲ្យខ្ញុំដែរឬទេ?

នាយកដ្ឋានស្ថានីតិសម្បទា នឹងជ្រោមជ្រែងជម្រើសរបស់បុគ្គលដែលមានសិទ្ធិទទួលសេវាកម្ម ដើម្បីបង្កើតផែនការមុខរបរផ្ទាល់ខ្លួន លុះត្រាតែខ្លួនបានកំណត់ឃើញថា មុខរបរផ្ទាល់ខ្លួនដែលបានស្នើឡើងមានភាពសមរម្យ ។ 9 C.C.R. វគ្គទី 7136.6(a) ។ ដើម្បីធ្វើឲ្យផែនការមុខរបរផ្ទាល់ខ្លួនមានភាពសមរម្យ អ្នកត្រូវមានចំណុចទាំងអស់ដូចខាងក្រោម ៖

- ផែនការមុខរបរផ្ទាល់ខ្លួន មានភាពស្របគ្នាជាមួយនឹងភាពខ្លាំងធនធាន អាទិភាព កង្វល់ លទ្ធភាព សមត្ថភាព ចំណាប់អារម្មណ៍ និងជម្រើសរបស់អ្នកដែលអ្នកបានដឹង

- វាហាក់ដូចជាសមហេតុផលដែលថា មុខរបរនោះ ដែលជាមុខរបរផ្ទាល់ខ្លួនរបស់អ្នក នឹងអាចបង្កើតបាននូវប្រាក់ចំណូលគ្រប់គ្រាន់ក្នុងរយៈពេល 12 ខែ និង

- សាមីខ្លួនមានលទ្ធភាពទទួលបានធនធានទាំងអស់ដែលចាំបាច់ក្នុងការរៀបចំ និងជ្រោមជ្រែងមុខរបរនោះ ។

9 C.C.R. វគ្គទី 7136.6(b)(1)-(3) ។

## 20. តើផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់ខ្ញុំត្រូវពិនិត្យឡើងវិញញឹកញាប់ប៉ុណ្ណា?

អ្នកមានសិទ្ធិឲ្យគេពិនិត្យផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់អ្នក ជាផ្លូវការ ជាមួយនឹងអ្នកប្រឹក្សាយោបល់របស់អ្នក ចំនួនមួយដងក្នុងមួយឆ្នាំ ។ 29 U.S.C. វគ្គទី 722(b)(2)(E)(i) 34 C.F.R. វគ្គទី 361.45(d)(5) 9 C.C.R. វគ្គទី

7133(a). នេះជាឱកាសរបស់អ្នក ដែលត្រូវយកមកគិតពិចារណាចំពោះការផ្លាស់ប្តូរណាមួយ ដែលបានកើតឡើងកាលពីឆ្នាំមុន ។ នៅក្នុងដំណើរការពិនិត្យឡើងវិញនេះ ត្រូវកត់ត្រាទុកអំពីការរីកចម្រើនរបស់អ្នក ហើយត្រូវពិចារណាចំពោះកត្តាផ្សេងៗទៀត ដែលមានផលប៉ះពាល់ចំពោះលទ្ធផលនៃផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់អ្នក ។ ឧទាហរណ៍ អ្នកអាចប្តូរគោលបំណងរយៈពេលខ្លីរបស់អ្នក ឬក្របខ័ណ្ឌពេលវេលាសម្រាប់ការសម្រេចបាននូវគោលបំណង បើស្ថានភាពវេជ្ជសាស្ត្ររបស់អ្នកមានការផ្លាស់ប្តូរ ។ សូមអានចំណុចទូទៅនៃ 9 C.C.R. វគ្គទី 7133 ។

## 21. តើត្រូវធ្វើដូចម្តេចបើខ្ញុំមិនយល់ស្របជាមួយនឹងរបៀបដែលគេកែប្រែខ្លឹមសារនៅក្នុងផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់ខ្ញុំ?

អ្នកអាចពិភាក្សាជាមួយនឹងអ្នកប្រឹក្សាយោបល់មកពីនាយកដ្ឋានស្តានីតិសម្បទារបស់អ្នក ដើម្បីកែប្រែផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់អ្នក ។ 29 U.S.C. វគ្គទី 722(b)(2)(E)(ii) 34 C.F.R. វគ្គទី 361.45(d)(6) 9 C.C.R. វគ្គទី 7130(a)(6) ។ ការកែប្រែផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់អ្នក នឹងមិនមានសុពលភាពឡើយ បើអ្នកមិនបានយល់ព្រមជាមួយនឹងការកែប្រែនេះ ហើយមិនបានចុះហត្ថលេខាចំពោះកិច្ចព្រមព្រៀងថ្មីទេនោះ ។ 34 C.F.R. វគ្គទី 361.45(d)(7) ។

## 22. ខ្ញុំបានទទួលបែបបទសំបុត្រឲ្យទៅធ្វើការ (Ticket to Work) ពីរដ្ឋបាលបេឡាសន្តិសុខសង្គម ។ តើវាជាបែបបទអ្វីទៅ?

សំបុត្រ ដែលចេញដោយរដ្ឋបាលបេឡាសន្តិសុខសង្គម (SSA, Social Security Administration) អាចយកទៅប្រើដើម្បីទទួលបានសេវាកម្មការងារ សេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈ និងសេវាកម្មជ្រោមជ្រែងដទៃទៀតពីនាយកដ្ឋានស្តានីតិសម្បទា ឬពីបណ្តាញការងារផ្សេងទៀតទៅតាមជម្រើសរបស់អ្នក ដើម្បីឲ្យអ្នកអាចរកការងារបានធ្វើ ។

## 23. តើអ្វីជាបណ្ដាញការងារ?

បណ្ដាញការងារ (Employment Network) គឺជាអ្នកផ្ដល់សេវាកម្មការងារដែលជាភ្នាក់ងាររបស់រដ្ឋ ឬភ្នាក់ងារឯកជនដែលបានទទួលការអនុម័តិ ដែលនឹងទទួលបានសិទ្ធិឲ្យទទួលយកសំបុត្ររបស់អ្នក និងផ្ដល់សេវាកម្មនានាដែលចាំបាច់ ដើម្បីជួយអ្នកឲ្យអាចរកការងារធ្វើ បាន ។ សេវាកម្មទាំងនេះ អាចរួមបញ្ចូលនូវ តែក៏មិនកំណត់តែចំពោះការបណ្ដុះបណ្ដាល ការប្រឹក្សាយោបល់ការងារ ការរៀបចំជំនាញស្វែងរកការងារ និងការបញ្ជូនអ្នកឲ្យទៅធ្វើការ ។

សម្រាប់បញ្ជីឈ្មោះបណ្ដាញការងារក្នុងមូលដ្ឋានដែលបានទទួលការអនុម័តិ សូមហៅទូរស័ព្ទមកលេខ 1-866-968-7842 ឬលេខ 1-866-833-2968 (TTY/TDD) ឬចូលទៅកាន់អាសយដ្ឋាន http://www.yourtickettowork.com

## 24. តើត្រូវធ្វើដូចម្ដេចបើបច្ចុប្បន្ន ខ្ញុំជាបុគ្គលិកបម្រើការនៅនាយកដ្ឋានស្ថានីតិសម្បទា?

អ្នកអាចបន្តធ្វើការនៅទីនោះ ដោយមិនមានការរំខានអ្វីឡើយ ។ នៅពេលអ្នក និងអ្នកប្រឹក្សាយោបល់របស់អ្នក បានបង្កើតផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ អ្នកនឹងទទួលបានការលើកទឹកចិត្តឲ្យចាត់សំបុត្ររបស់អ្នកទៅកាន់នាយកដ្ឋាន ។ ទោះជាយ៉ាងណាក៏ដោយ អ្នក*មិនត្រូវ*បានតម្រូវថា អ្នកត្រូវតែចាត់លិខិតរបស់អ្នកទៅកាន់នាយកដ្ឋានស្ថានីតិសម្បទាឡើយ ។

## 25. តើខ្ញុំនឹងត្រូវរងការពិន័យដែរឬទេ ប្រសិនបើខ្ញុំសម្រេចមិនប្រើសំបុត្រនោះ?

ទេ ។ ការចាត់សំបុត្ររបស់អ្នកទៅកាន់នាយកដ្ឋានស្ថានីតិសម្បទា គឺជាការស្ម័គ្រចិត្ត ហើយអ្នកនឹងមិនត្រូវរងការពិន័យអ្វីឡើយ ។

## 26. តើខ្ញុំអាចទទួលបានសំណៅកំណត់ត្រាព័ត៌មានរបស់ខ្ញុំដោយរបៀបណា?

យោងទៅតាមច្បាប់សហព័ន្ធ ខាងនាយកដ្ឋានត្រូវ បញ្ចេញព័ត៌មានមកឲ្យអ្នកដាក់ពាក្យសុំ ឬអ្នកដែលមានសិទ្ធិទទួលសេវាកម្ម នៅពេលដែលអ្នកដាក់ពាក្យ ឬអ្នកដែលមានសិទ្ធិទទួល

សេវាកម្មធ្វើការស្នើសុំ**ជាលាយលក្ខណ៍អក្សរ** ។ 34 C.F.R. វគ្គទី 361.38(c)(1) ។ ស្ថិតក្រោមបទបញ្ញត្តិរបស់រដ្ឋកាលីហ្វ័រនីញ៉ា អ្នកដាក់ពាក្យ ឬអតិថិជន អាចទទួលបានកំណត់ត្រាព័ត៌មានរបស់ខ្លួនពីនាយកដ្ឋាន ទៅតាមការស្នើសុំ ។ 9 C.C.R. វគ្គទី 7141(a) ។ នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា ចំពោះការស្នើសុំព័ត៌មានបែបនេះ គឺមិនតម្រូវឲ្យមានការសរសេរពាក្យសុំជាលាយលក្ខណ៍អក្សរឡើយ ទោះជាយ៉ាងណាក៏ដោយ វាអាចជាវិធីដ៏ប្រសើរបំផុត ប្រសិនបើ អ្នកស្នើសុំកំណត់ត្រាព័ត៌មានរបស់អ្នកជាលាយលក្ខណ៍អក្សរ ។ សូមអាន ចំណុចទូទៅនៃ 9 C.C.R. វគ្គទី 7141 ។

អ្នកមានសិទ្ធិទទួលបានសំណៅថតចម្លងផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់អ្នកដោយពេញលេញ និងបរិបូរណ៍ ។ 29 U.S.C. វគ្គទី 722(b)(2)(D) ។ តាមពិតទៅ អ្នកមានសិទ្ធិទទួលបានកំណត់ត្រាសំណុំរឿងរបស់អ្នកទាំងមូល ដោយមានការលើកលែងមួយចំនួនតូច សូមអានសំណួរទី 27 ខាងក្រោម ។ 9 C.C.R. វគ្គទី 7141(a) ។

សម្រាប់ព័ត៌មានបន្ថែម អំពីការទទួលបានកំណត់ត្រាពីនាយកដ្ឋាន ស្តារនីតិសម្បទា សូមអាន ឯកសារការពិតស្តីអំពី ការស្នើសុំកំណត់ត្រាព័ត៌មានពីនាយកដ្ឋានស្តារនីតិសម្បទា (Request for Department of Rehabilitation [DOR] Records Fact Sheet) អត្ថបទបោះពុម្ពផ្សាយលេខ 553301 ៖ http://www.disabilityrightsca.org/pubs/553301.pdf

## 27. នាយកដ្ឋានស្តារនីតិសម្បទានិយាយថា គេមិនអាចឲ្យកំណត់ត្រាព័ត៌មានរបស់ខ្ញុំ មកខ្ញុំបានទេ ។ តើពួកគេអាចរក្សាកំណត់ត្រាព័ត៌មាននោះទុក មិនឲ្យខ្ញុំបានទេ?

នាយកដ្ឋានស្តារនីតិសម្បទា អាចបដិសេធមិនបញ្ចេញព័ត៌មានឲ្យអ្នក ក្រោមកាលៈទេសៈមួយចំនួន ។ ឧទាហរណ៍ បើនាយកដ្ឋានស្តារនីតិសម្បទា កំណត់ឃើញថា ព័ត៌មាននោះ “អាចមានគ្រោះថ្នាក់ចំពោះសាមីខ្លួន” (“may be harmful to the individual”) ពួកគេអាចបដិសេធមិន បញ្ចេញព័ត៌មាននោះឲ្យអ្នកបាន ។ បើទោះបីជាស្ថិតក្រោមកាលទេសៈនេះក៏ដោយ ក៏ព័ត៌មាននោះត្រូវតែផ្តល់ឲ្យអ្នកដាក់ពាក្យ ឬសាមីខ្លួនតាមរយៈភាគីទីបីដែរ ។ 34 C.F.R. វគ្គទី 361.38(c)(2; 9 C.C.R. វគ្គទី 7141(c) ។

## 28. តើខ្ញុំអាចសុំព័ត៌មាននោះជាភាសាដទៃក្រៅពីភាសាអង់គ្លេសបានដែរឬទេ?

អាច ។ សូមប្រាប់អ្នកប្រឹក្សាយោបល់របស់អ្នកដែលមកពីនាយកដ្ឋានស្តានីតិសម្បទាឲ្យបានដឹងថា អ្នកត្រូវការឲ្យគេបកប្រែកំណត់ត្រាព័ត៌មានរបស់អ្នក ។ អ្នកប្រឹក្សាយោបល់នឹងជួយអ្នក យកកំណត់ត្រាព័ត៌មាននោះឲ្យគេបកប្រែជាភាសាដែលអ្នកអាចយល់បាន ។ 9 C.C.R. វគ្គទី 7141(b) ។

## 29. តើខ្ញុំអាចកែប្រែកំណត់ត្រាផ្តល់សេវាកម្មចំពោះខ្ញុំបានដែរឬទេ?

បើអ្នកជឿថា ព័ត៌មាននៅក្នុងកំណត់ត្រាព័ត៌មានរបស់អ្នកមិនត្រឹមត្រូវនោះ អ្នកអាចស្នើសុំឲ្យមានការកែប្រែឡើងវិញ ។ 9 C.C.R. វគ្គទី 7141.5 (c) ។ ប្រសិនបើនាយកដ្ឋានស្តានីតិសម្បទាសម្រេចមិនកែប្រែកំណត់ត្រាព័ត៌មានទៅតាមការស្នើសុំរបស់អ្នកទេ គេត្រូវធ្វើកំណត់ត្រាអំពីការស្នើសុំរបស់អ្នកសម្រាប់ធ្វើការកែប្រែនៅពេលក្រោយ ។ 34 C.F.R. វគ្គទី 361.38(c)(4) 9 C.C.R. វគ្គទី 7141.5(e) ។

## 30. តើខ្ញុំត្រូវធ្វើអ្វីទៀត បើខ្ញុំមានបញ្ហាជាមួយនឹងអ្នកប្រឹក្សាយោបល់របស់ខ្ញុំដែលមកពីនាយកដ្ឋានស្តានីតិសម្បទា?

សូមព្យាយាមដោះស្រាយបញ្ហាជាមួយនឹងអ្នកប្រឹក្សាយោបល់ ។ ប្រហែលជាប្រធានរបស់អ្នកប្រឹក្សាយោបល់ ឬអ្នកចាត់ចែងក្រុម អាចជួយអ្នកបានក្នុងការដោះស្រាយបញ្ហាអ្វីមួយ ។ អ្នកអាចស្នើសុំការប្រជុំជាមួយនឹងប្រធានរបស់អ្នកប្រឹក្សាយោបល់ ។ បើអ្នកនៅតែមិនអាចដោះស្រាយបញ្ហា ជាមួយនឹងប្រធានរបស់អ្នកប្រឹក្សាយោបល់បានទេ អ្នកអាចស្នើសុំប្រធានរដ្ឋបាលឪស្រ្ទិក (District Administrator) ឲ្យធ្វើការពិនិត្យសំណុំរឿងជាលក្ខណៈរដ្ឋបាល (Administrative Review) ឡើងវិញ ។ ការពិនិត្យសំណុំរឿងជាលក្ខណៈរដ្ឋបាល គឺជាជម្រើសនៃជំហានចំពោះដំណើរការប្តឹងឧទ្ធរណ៍ ហើយអ្នកត្រូវស្នើសុំឲ្យបានក្នុងរង្វង់មួយឆ្នាំនៃសេចក្តីសម្រេចដែលអ្នកមិនយល់ព្រម ។ បើអ្នករង់ចាំយូរពេក ដើម្បីស្នើសុំឲ្យមានការពិនិត្យសំណុំរឿងជាលក្ខណៈរដ្ឋបាល អ្នកអាចបាត់បង់ឱកាសប្តឹងឧទ្ធរណ៍អំពីការសម្រេចនេះ ។

បើអ្នកមិនពេញចិត្តចំពោះលទ្ធផលការពិនិត្យសំណុំរឿងជាលក្ខណៈរដ្ឋបាល អ្នកអាចស្នើសុំឲ្យមានការសម្រុះសម្រួល និង/ឬសវនាការយុត្តិធម៌ (Fair Hearing) ។ អ្នកត្រូវដាក់ពាក្យសុំនេះជា***លាយល័ក្ខណ៍អក្សរ***ដោយបំពេញបែបបទ ពាក្យសុំ DR107 សម្រាប់ការសម្រុះសម្រួល និង/ឬបែបបទស្នើសុំសវនាការយុត្តិធម៌ (DR107 Request for Mediation and/or Fair Hearing form) ***ឲ្យបានក្នុងរវាង 30 ថ្ងៃ*** គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនៃការធ្វើការពិនិត្យសំណុំរឿងជាលក្ខណរដ្ឋបាលឡើងវិញ ។ 9 C.C.R. វគ្គទី 7353(f) ។

សម្រាប់ព័ត៌មានបន្ថែម ស្តីអំពីសិទ្ធិប្តឹងឧទ្ធរណ៍របស់អ្នក សូមអានឯកសារការពិតស្តីអំពីជម្រើស និងដំណើរការចំពោះការប្តឹងឧទ្ធរណ៍ចំពោះនាយកដ្ឋានស្តានីតិសម្បទារដ្ឋកាលីហ្វ័រនីញ៉ា (California Department of Rehabilitation Appeals Options & Process Fact Sheet) ឯកសារបោះពុម្ពផ្សាយលេខ 553001
http://www.disabilityrightsca.org/pubs/553001.pdf

អ្នកអាចទាក់ទងជាមួយនឹងអ្នកតស៊ូមតិកម្មវិធីផ្តល់ជំនួយដល់អតិថិជន (CAP, Client Assistance Program) របស់អ្នក ដើម្បីស្នើសុំជំនួយ ។ (*សូមអាន*សំណួរទី 36 និង 37 ខាងក្រោម ដើម្បីបានដឹងព័ត៌មានបន្ថែមអំពី CAP) ។ អ្នកតស៊ូមតិកម្មវិធីផ្តល់ជំនួយដល់អតិថិជន ប្រហែលជាអាចជួយអ្នកបានក្នុងការដោះស្រាយបញ្ហារបស់អ្នកជាមួយនឹងនាយកដ្ឋានស្តានីតិសម្បទា ។

## 31. តើត្រូវធ្វើដូចម្តេចបើខ្ញុំមិនចេះភាសាអង់គ្លេស ឬបើខ្ញុំត្រូវការអ្នកបកប្រែភាសាសញ្ញា?

អ្នកអាចសុំឲ្យគេផ្ញើសេចក្តីជូនដំណឹងមកឲ្យអ្នកជាភាសាបឋមរបស់អ្នក ឬអ្នកអាចស្នើសុំឲ្យគេផ្ញើដំណឹងមកអ្នកទៅតាមបែបផែននៃការទំនាក់ទំនងដែលអ្នកចង់បាន ។ នៅពេលដែលអ្នកបានស្នើសុំយ៉ាងជាក់លាក់ហើយ នាយកដ្ឋានស្តានីតិសម្បទា ត្រូវផ្ញើដំណឹង និងការសម្រេចរបស់ខ្លួនមកឲ្យអ្នកជាភាសាកំណើតរបស់អ្នក ឬទៅតាមបែបផែននៃការទំនាក់ទំនងដែលអ្នកចង់បាន ។ W.I.C. វគ្គទី 19013.5(a)-(b) និង 9 C.C.R. វគ្គទី 7352(a) ។

## 32. តើខ្ញុំអាចស្នើសុំការពិនិត្យសំណុំរឿងតាមបែបរដ្ឋបាលដោយវិធីណា?

អ្នកត្រូវស្នើសុំការពិនិត្យសំណុំរឿងតាមបែបរដ្ឋបាល ក្នុងរវាងមួយឆ្នាំចំពោះការសម្រេចណាមួយដែលអ្នកមិនពេញចិត្ត ។ សំណើសុំរបស់អ្នក អាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរ ហើយត្រូវរួមបញ្ចូលព័ត៌មានដូចខាងក្រោម ៖

- មូលហេតុដែលអ្នកគិតថាត្រូវប្តូរការសម្រេចចិត្ត និង
- តើវិធានការណ៍អ្វីដែលអ្នកស្នើឲ្យអនុវត្ត ។

9 C.C.R. វគ្គទី 7353(a)(2) និង (3) ។

នាយកដ្ឋានស្ដានីតិសម្បទា ត្រូវតែផ្តល់ឲ្យអ្នកនូវសេចក្តីសម្រេចជាលាយល័ក្ខណ៍អក្សរ ស្តីអំពីបញ្ហាក្នុងការស្នើសុំរបស់អ្នក ឲ្យបានក្នុងរវាង 15 ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទដែលអ្នកបានស្នើសុំឲ្យមានការពិនិត្យសំណុំរឿងឡើងវិញតាមបែបរដ្ឋបាល ។ 9 C.C.R. វគ្គទី 7353(f) ។

## 33. បើខ្ញុំមិនចេះនិយាយភាសាអង់គ្លេស តើនាយកដ្ឋាននឹងជួយខ្ញុំក្នុងពេលពិនិត្យសំណុំរឿងឡើងវិញតាមបែបរដ្ឋបាលដែរឬទេ?

អាច ។ សេវាកម្មអ្នកបកប្រែ និងសេវាកម្មអ្នកអាន ត្រូវតែផ្តល់ឲ្យអ្នកក្នុងពេលដំណើរការពិនិត្យសំណុំរឿងឡើងវិញតាមបែបរដ្ឋបាល ។ វាអាស្រ័យលើអ្នកក្នុងការស្នើសុំសេវាកម្មទាំងអស់នេះ ។ 9 C.C.R. វគ្គទី 7353(c) ។ ពេលអ្នកស្នើសុំជំនួយផ្នែកភាសា អ្នកត្រូវដឹងឲ្យច្បាស់ថា តើអ្នកត្រូវការអ្វី ។ បើអ្នកត្រូវការអ្នកបកប្រែភាសា អ្នកត្រូវតែប្រាកដខ្លួនឯងអំពីតម្រូវការនេះ ។ បើអ្នកត្រូវការទទួលដំណឹង និងសេចក្តីសម្រេចជាភាសាដទៃក្រៅពីភាសាអង់គ្លេស អ្នកត្រូវប្រាកដខ្លួនឯងអំពីតម្រូវការមួយនេះដែរ ។

## 34. តើខ្ញុំអាចស្នើសុំមធ្យោបាយធ្វើដំណើរ ទៅកាន់កន្លែងធ្វើការពិនិត្យសំណុំរឿងតាមបែបរដ្ឋបាល និងការត្រឡប់មកផ្ទះវិញបានដែរឬទេ?

អាច ។ អ្នកអាចស្នើសុំនាយកដ្ឋានស្ថានីតិសម្បទា ឲ្យផ្តល់ឲ្យអ្នក នូវមធ្យោបាយធ្វើដំណើរទៅកាន់កន្លែងពិនិត្យសំណុំរឿងតាមបែបរដ្ឋបាល និងត្រឡប់មកផ្ទះវិញ ។ 9 C.C.R. វគ្គទី 7353(d) ។

## 35. តើការពិនិត្យសំណុំរឿងឡើងវិញតាមបែបរដ្ឋបាល ជាអ្វីដែលត្រូវតែធ្វើមែនទេ?

ទេ ។ ដំណើរការពិនិត្យសំណុំរឿងតាមបែបរដ្ឋបាល គឺជាជម្រើស ។ អ្នកអាច ស្នើសុំភ្លាមៗ ឲ្យធ្វើការសម្រុះសម្រួល និង/ឬ សវនាការយុត្តិធម៌ ។ 9 C.C.R. វគ្គទី 7351(c) ។

## 36. តើការសម្រុះសម្រួលជាអ្វីដែលត្រូវតែធ្វើមែនទេ?

ទេ ។ ការសម្រុះសម្រួលក៏ជាជម្រើសផងដែរ ។ 34 C.F.R. វគ្គទី 361.57(d)(2)(i) ។ វាជាដំណើរការសម្ងាត់ ដែលអាចជួយអ្នកក្នុងការដោះស្រាយវិវាទរបស់អ្នក ជាមួយនឹងនាយកដ្ឋានស្ថានីតិសម្បទា ។ ដូចគ្នាទៅនឹងដំណើរការពិនិត្យសំណុំរឿង ឡើងវិញតាមបែបរដ្ឋបាលផងដែរ ការសម្រុះសម្រួល វាមិនមែនជាការពន្យាសិទ្ធិរបស់អ្នកដើម្បីស្នើសុំសវនាការយុត្តិធម៌ឡើយ ។ 9 C.C.R. វគ្គទី 7353.6(b) 34 C.F.R. វគ្គទី 361.57(d)(2)(ii) ។

អ្នកអាចស្នើសុំការសម្រុះសម្រួលចំពោះសេចក្តីសម្រេចដែលធ្វើឡើងដោយ នាយកដ្ឋាន ដែលអ្នកមិនយល់ស្របជាមួយ ឲ្យបានក្នុងរវាងមួយឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចដែលបានធ្វើឡើង ឬមួយបើអ្នកបានចូលរួមក្នុងដំណើរការ ពិនិត្យសំណុំរឿងឡើងវិញតាមបែបរដ្ឋបាល ក្នុងរវាង 30 ថ្ងៃនៃការ ពិនិត្យឡើងវិញនូវសំណុំរឿងតាមបែបរដ្ឋបាល ។ សំណើសុំធ្វើការសម្រុះសម្រួល ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយប្រើបែបបទពាក្យសុំ DR107 សម្រាប់ការសម្រុះសម្រួល និង/ឬបែបបទស្នើសុំសវនាការយុត្តិធម៌ ដែលអ្នក អាចស្នើសុំពីការិយាល័យនាយកដ្ឋានស្ថានីតិសម្បទា ក្នុងមូលដ្ឋានរបស់អ្នក ។ 9 C.C.R. វគ្គទី 7353(f) និង 7353.6(a)(1)-(2) ។

បើនាយកដ្ឋានយល់ព្រមសម្រុះសម្រួល ការសម្រុះសម្រួលនឹងត្រូវធ្វើឡើងទៅតាមពេលវេលា និងទីកន្លែងដែលសមរម្យសម្រាប់ភាគីទាំងអស់ ក្នុងរវាង 25 ថ្ងៃតាមប្រតិទិន ដោយគិតចាប់ពីពេលដែលសំណើសុំត្រូវបានធ្វើឡើង ។ 9 C.C.R. វគ្គទី 7353.6(b)-(c) 34 C.F.R. វគ្គទី 361.57(d) ។

ដើម្បីភាពងាយស្រួលរបស់អ្នក អ្នកអាចរកមើលបែបបទ ពាក្យសុំសម្រុះសម្រួលគំរូរបស់នាយកដ្ឋានស្តានីតិសម្បទា នៅឯ ៖ http://www.dor.ca.gov/Executive/Mediation.html

## 37. ចុះដំណើរការសវនាការយុត្តិធម៌វិញ មានភាពដូចម្តេចដែរ?

អ្នកអាចស្នើសុំសវនាការយុត្តិធម៌ ដើម្បីពិនិត្យឡើងវិញនូវសកម្មភាព ឬភាពមិនសកម្មរបស់នាយកដ្ឋាន ។ អ្នកត្រូវស្នើសុំសវនាការយុត្តិធម៌ ជាលាយល័ក្ខណ៍អក្សរ ឲ្យបានក្នុងរវាងមួយឆ្នាំ ដោយគិតចាប់ពីពេលដែលមាន សកម្មភាព ឬភាពអសកម្មដែលអ្នកមិនយល់ស្រប ។ 9 C.C.R. វគ្គទី 7354(a) ។ បើអ្នកបានចូលរួមក្នុងដំណើរការពិនិត្យសំណុំរឿងឡើងវិញតាមបែបរដ្ឋបាល អ្នកត្រូវស្នើសុំឲ្យបានក្នុងរវាង 30 គិតចាប់ពីពេលចេញសេចក្តីសម្រេចនៃការ ពិនិត្យសំណុំរឿងឡើងវិញតាមបែបរដ្ឋបាល ។ 9 C.C.R. វគ្គទី 7353(f) ។ សវនាការនឹងត្រូវធ្វើឡើងក្នុងរវាង 60 ថ្ងៃតាមប្រតិទិន គិតចាប់ពីពេលដែលយើងខ្ញុំបានទទួលសំណើរបស់អ្នក ។ 9 C.C.R.  វគ្គទី 7354(b) ។

ដើម្បីភាពងាយស្រួលរបស់អ្នក អ្នកអាចរកមើល ពាក្យស្នើសុំសវនាការគំរូរបស់នាយកដ្ឋានស្តានីតិសម្បទាបាននៅឯ ៖ http://www.dor.ca.gov/Appeals/index.html

សម្រាប់ព័ត៌មានបន្ថែម ស្តីអំពីរបៀបរៀបចំសវនាការយុត្តិធម៌របស់អ្នក សូមអាន ៖ *របៀបត្រៀមខ្លួនសម្រាប់សវនាការរបស់នាយកដ្ឋានស្តានីតិសម្បទា,* អត្ថបទបោះពុម្ពផ្សាយលេខ 553201 ៖ http://www.disabilityrightsca.org/pubs/553201.pdf

## 38. តើនាយកដ្ឋានអាចកាត់ផ្តាច់សេវាកម្មដែលខ្ញុំកំពុងទទួលបាន រហូតដល់មានសេចក្តីសម្រេចដែរឬទេ?

ទេ ។ 
រហូតដល់មានសេចក្តីសម្រេចនៃការពិនិត្យឡើងវិញនូវសំណុំរឿងតាមបែបរដ្ឋបាល

ឬរហូតដល់ការិយាល័យសវនាការរដ្ឋបាល (Office of Administrative Hearings) ផ្តល់សេចក្តីសម្រេច នាយកដ្ឋានមិនអាចពន្យារ កាត់បន្ថយ ឬបញ្ចប់ សេវាកម្មណាមួយ ដែលអ្នកកំពុងបានទទួលក្រោមផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់អ្នកឡើយ ។ 29 U.S.C. វគ្គទី 722(c);)(7) 34 C.F.R. វគ្គទី 361.57(b)(4) 9 C.C.R. វគ្គទី 7351(e) ។

## 39. តើអ្វីជាកម្មវិធីសម្រាប់ជួយអតិថិជន (CAP)?

កម្មវិធីសម្រាប់ជួយអតិថិជន (CAP) ជាកម្មវិធីដែលកំណត់ដោយរដ្ឋាភិបាលសហព័ន្ធ ក្រោមក្រមស្តានីតិសម្បទា ឆ្នាំ 1973 ។ 29 U.S.C.  701, *et seq* ។  CAP ជាកម្មវិធីសម្រាប់ជួយអ្នកឲ្យយល់បាននូវសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក ពាក់ព័ន្ធនឹង សិទ្ធិទទួលសេវាកម្មពីនាយកដ្ឋានស្តានីតិសម្បទា។  ការតស៊ូមតិរបស់ កម្មវិធីសម្រាប់ជួយអ្នកអតិថិជន ប្រហែលជាអាចជួយអ្នកក្នុងការដោះស្រាយបញ្ហារបស់អ្នកជាមួយនឹងនាយកដ្ឋានស្តានីតិសម្បទា ឬអាចជួយអ្នក និង តស៊ូមតិជំនួសរូបអ្នក ពាក់ព័ន្ធនឹងសេវាកម្មវិជ្ជាជីវៈ ក្នុងពេល អ្នកកំពុងរកដំណោះស្រាយតាមផ្លូវច្បាប់ តាមបែបរដ្ឋបាល ឬជួយអ្នកក្នុងការទទួលបានដំណោះស្រាយផ្សេងដែលសមរម្យ ដើម្បីធានាបានចំពោះការការពារសិទ្ធិអ្នក ។ សូមអានវគ្គទូទៅនៃ  29 U.S.C. វគ្គទី 732 ។

ព័ត៌មានបន្ថែមអំពីកម្មវិធីសម្រាប់ជួយអតិថិជន មាននៅឯ ៖ http://www.disabilityrightsca.org/about/cap.html

ដើម្បីទាក់ទង ជាមួយនឹងកម្មវិធីសម្រាប់ជួយអតិថិជន (CAP) នៅឯ Disability Rights California អ្នកអាចហៅទូរស័ព្ទមកលេខ 1-800-776-5746 ។

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្តល់ជំនួយនានាមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html* ។